## ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ផ្សារមូលបត្រកម្ពុជា

CSX

ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា

*ថ្ងៃ ពុធ ១៣ រោច ខែ អស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧*

*រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០២៤*

### សេចក្តីជូនដំណឹង

### ក្រុមហ៊ុនមូលបត្រ អេស៊ីលីដា ម.ក ឈ្នះជ័យលាភីឈ្មួញជើងសាមូលបត្រឆ្នើមសម្រាប់ត្រីមាសទី៣ ឆ្នាំ២០២៤

ផ្សារមូលបត្រកម្ពុជា **(ផមក)** មានកិត្តិយសសូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា ជ័យលាភីឈ្មួញជើងសាមូលបត្រឆ្នើម សម្រាប់ត្រីមាសទី៣ ឆ្នាំ២០២៤ គឺបានទៅលើ **ក្រុមហ៊ុនមូលបត្រ អេស៊ីលីដា ម.ក** ។ លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ធ្វើការវាយតម្លៃមានដូចខាងក្រោម៖

| | |
|---|---|
| ១. ទំហំជួញដូរមូលបត្រសរុបរបស់អតិថិជន | ៣០ ពិន្ទុ |
| ២. ចំនួនគណនីជួញដូរដែលបានបើកថ្មី | ២០ ពិន្ទុ |
| ៣. សកម្មភាពជំរុញការជួញដូរមូលបត្រ | ៣០ ពិន្ទុ |
| ៤. កម្មវិធីជំរុញការជួញដូរមូលបត្រ | ២០ ពិន្ទុ |

តាមរយៈលក្ខខណ្ឌវិនិច្ឆ័យខាងលើ **ក្រុមហ៊ុនមូលបត្រ អេស៊ីលីដា ម.ក** បានជាប់ជាជ័យលាភីក្នុងចំណោមឈ្មួញជើងសាមូលបត្រទាំង ១២។

នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ នេះ ទំហំជួញដូរមូលបត្រសរុបរបស់អតិថិជនតាមរយៈ **ក្រុមហ៊ុនមូលបត្រ អេស៊ីលីដា ម.ក** មានចំនួន ៤៩ ពាន់លានរៀល ពោលគឺស្មើនឹង ៧៥,៦៨% នៃទំហំជួញដូរមូលបត្រសរុប ហើយគណនីជួញដូរថ្មីដែលបានបើកជាមួយក្រុមហ៊ុន មានចំនួន ១.២០៣ គណនី។ **ក្រុមហ៊ុនមូលបត្រ អេស៊ីលីដា ម.ក** មានភាពសកម្មក្នុងការសហការជាមួយដៃគូនានា ក្នុងការរៀបចំព្រឹត្តិការណ៍ដែលទទួលបានការចូលរួមពីសាធារណជនជាច្រើន ក៏ដូចជាបានផ្តល់នូវកម្មវិធីពិសេសដល់អតិថិជនថ្មី ក្នុងគោលបំណងអប់រំ ផ្សព្វផ្សាយ និងជំរុញសកម្មភាពជួញដូរមូលបត្រ។

គួររំលឹកផងដែរថា កម្មវិធីឈ្មួញជើងសាមូលបត្រឆ្នើមនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងស្វែងរកនូវក្រុមហ៊ុនឈ្មួញជើងសាមូលបត្រឆ្នើមប្រចាំត្រីមាសនីមួយៗ ដែលមានភាពឈានមុខគេ ក្នុងការផ្តល់សេវាកម្មឈ្មួញជើងសាមូលបត្រសម្រាប់អតិថិជនរបស់ខ្លួន និង មានការខិតខំប្រឹងប្រែង ក្នុងការជំរុញសកម្មភាពជួញដូរក្នុងទីផ្សារ។

ផ្សារមូលបត្រកម្ពុជា

Cambodia Securities Exchange CSX

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក ព្រៃ សុភាឫទ្ធិវិជ្ជា មន្ត្រីប្រតិបត្តិ

នាយកដ្ឋានប្រតិបត្តិការទីផ្សារ

អ៊ីម៉ែល៖ sophearithvichea.prey@csx.com.kh